បានទទួលដំណឹង។ បានចូលរួម។ បានរាប់ចំនួន។

# សៀវភៅណែនាំ ការធ្វើជំរឿនឆ្នាំ2020 របស់អ្នកសម្រាប់អ្នកផ្តល់សេវាសុខភាព

## ហេតុអ្វីបានជាការធ្វើជំរឿនមានភាពចាំបាច់សម្រាប់អ្នកផ្តល់សេវាសុខភាព?

គ្លីនិក ក្រុមហ៊ុនធានារ៉ាប់រង រដ្ឋាភិបាលក្នុងស្រុក និងសកលវិទ្យាល័យ ពឹងផ្អែកលើទិន្នន័យជំរឿនដើម្បីធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីគោលនយោបាយ ការវាយតម្លៃពីតម្រូវការសហគមន៍ និងច្រើនផ្សេងទៀត។

យោងតាម ការប៉ាន់ស្មានលើការធ្វើជំរឿនប្រជាជនឆ្នាំ2018 ឃើញថា 17.2% នៃពលរដ្ឋដែលរស់នៅទីក្រុង Los Angeles វ័យក្រោម 65 មិនមានការធានារ៉ាប់រងនោះទេ។ ព័ត៌មានពីទិន្នន័យជំរឿននេះផ្តល់មូលនិធិដល់ កម្មវិធីសំខាន់ៗ ដូចជាកម្មវិធី Medicaid កម្មវិធី Medicare ផ្នែក B កម្មវិធីអាហារបំប៉នសម្រាប់ស្ត្រី ទារក និងកុមារ (WIC) កម្មវិធីធានារ៉ាប់រងសុខភាពសម្រាប់កុមារ (CHIP) មណ្ឌលសុខភាព និងច្រើនផ្សេងទៀត។ នៅរដ្ឋកាលីហ្វញ៉ា (យោងតាមទិន្នន័យជំរឿនឆ្នាំ2010 "ការរាប់ចំនួនសម្រាប់ប្រាក់ដុល្លារ (Counting for Dollars) ឆ្នាំ2020"), បង្ហាញថាទឹកប្រាក់ជាង $55 ប៊ីលានត្រូវបានបែងចែកដល់កម្មវិធី Medicaid តែមួយមុខប៉ុណ្ណោះ។

## តើអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរថែទាំត្រូវបានរាប់ចំនួនដោយរបៀបណា?

មនុស្សគ្រប់គ្នា គប្បីត្រូវធ្វើការរាប់ចំនួននៅកន្លែងដែលពួកគេកំពុងស្នាក់នៅ និងគេងជាធម្មតានៅថ្ងៃឬមុនថ្ងៃទី1 ខែមេសា ឆ្នាំ2020 (ថ្ងៃធ្វើជំរឿន)។ មន្ទីរពេទ្យ និងមន្ទីរថែទាំត្រូវបានចាត់ទុកថាជាកន្លែងស្នាក់នៅ។ នៅដើមឆ្នាំ2020 អ្នកតំណាងក្រសួងជំរឿនសហរដ្ឋអាមេរិកនឹងព្យាយាមផ្តល់ជំនួយទៅដល់ថ្នាក់គ្រប់គ្រងរបស់អ្នកដើម្បីពិនិត្យមើលថាតើមន្ទីរវេជ្ជស្ថានរបស់អ្នកមានផែនការប្រគល់ទិន្នន័យដោយផ្ទាល់ទៅកាន់ក្រសួងជំរឿនដែរឬទេ ឬតើបុគ្គលិកដែលបានចាត់តាំង នឹងប្រមូលយកកម្រងសំណួរអំពីការធ្វើជំរឿនជាក្រដាសពីអ្នកជំងឺ ដែរទេ។

## តើកម្រងសំណួរនេះនឹងអាចស្វែងរកបានសម្រាប់អ្នកជំងឺ ដែលមិនចេះនិយាយភាសាអង់គ្លេសដែរឬទេ?

បាទ/ចាស។ តាមអនឡាញ កម្រងសំណួរនេះនឹងមានជា ភាសាទាំង 12 នេះ។ អេស្ប៉ាញ ចិន(អក្សរសាមញ្ញ) វៀតណាម កូរ៉េ រុស្ស៊ី អារ៉ាប់ តាកាឡុក ប៉ូឡូញ បារាំង ក្រេអូលហៃទី ព័រទុយហ្គាល់ និងជប៉ុន។ ខ្សែទូរសព្ទជំរឿនក៏នឹងផ្តល់ជំនួយជាភាសាទាំងនេះ និងឧបករណ៍ទំនាក់ទំនងសម្រាប់មនុស្សគថ្លង់។

កម្រងសំណួរលើក្រដាស នឹងអាចមានជាភាសាអង់គ្លេស និងអេស្ប៉ាញតែប៉ុណ្ណោះ។

សន្ទានុក្រមភាសា និងខ្សែវីដេអូ និងសៀវភៅណែនាំជាអក្សរពុម្ពដែលមានជាភាសាផ្សេងក្រៅភាសាអង់គ្លេសចំនួន 59 ភាសា រួមទាំងភាសាសញ្ញាអាមេរិកាំង អក្សរស្ទាប (Braille) និងអក្សរពុម្ពធំ។

ទីក្រុងLos Angeles និងផ្តល់ដំណោះស្រាយ(នានា) យ៉ាងសមស្រប ដើម្បីធានាការប្រើប្រាស់ដោយស្មើភាពគ្មាននូវកម្មវិធី សេវាកម្ម និងមន្ទីរវេជ្ជស្ថានរបស់ខ្លួនសម្រាប់មនុស្សដែលមានពិការភាព។ ដើម្បីធ្វើការស្នើសុំ សូមទាក់ទងទៅនាយកដ្ឋានផ្នែកពិការភាពតាមរយៈ DOD.Contact@lacity.org ឬ (213) 202-5668 ជាមុន ក្នុងរយៈពេលប្រាំថ្ងៃធ្វើការឬលើសពីនេះ។

Eric Garcetti @MayorOfLA

census.lacity.org
#2020Census